**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតអបអរសាទរ

## គោរពជូន
## ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក

**ឯកឧត្តម នាយឧត្តមសេនីយ៍ ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ!**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរប្រកបដោយទឹកចិត្តសប្បាយរីករាយក្រៃលែង ក្នុងឱកាសដែល **ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត** ទទួលនូវការបំពាក់ឋានន្តរស័ក្តិជា "**នាយឧត្តមសេនីយ៍**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**។

ការដំឡើងឋានន្តរស័ក្តិជា "**នាយឧត្តមសេនីយ៍**" នេះពិតជាស័ក្តិសមនឹងសមត្ថភាព ស្នាដៃ ចំណេះដឹង គុណធម៌ និងការលះបង់កម្លាំងកាយចិត្តយ៉ាងធំធេងដែលមិនអាចកាត់ថ្លៃបានរបស់ **ឯកឧត្តម នាយឧត្តមសេនីយ៍** ចំពោះជាតិមាតុភូមិ និងប្រជាជនកម្ពុជាប្រកបដោយទឹកចិត្តស្មោះសរ ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍនិងពង្រឹងសមត្ថភាពកងយោធពលខេមរភូមិន្ទ ក្នុងបុព្វហេតុការពារជាតិ សុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងវឌ្ឍនភាពសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីភាពរីកចម្រើន សុភមង្គល និងភាពសុខដុមរមនារបស់ប្រជាជាតិខ្មែរទាំងមូល។

ទឹកចិត្តនិងកាយវិការស្នេហាមាតុភូមិនិងប្រជាជនកម្ពុជារបស់ **ឯកឧត្តម នាយឧត្តមសេនីយ៍** ញ៉ាំងឱ្យយើងខ្ញុំប្តេជ្ញាគាំទ្រឥតងាករេនៅគ្រប់កាលៈទេសៈទាំងអស់ជាមួយឆន្ទៈដ៏មោះមុតចំពោះ **ឯកឧត្តម នាយឧត្តមសេនីយ៍** ក្នុងការចូលរួមរក្សាឱ្យបានជាដាច់ខាតនូវសុខសន្តិភាព វិបុលភាព និងសេចក្តីសុខក្សេមក្សាន្តជាដរាបរបស់ជាតិ និងប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយថែរក្សា ការពារ **ឯកឧត្តម នាយឧត្តមសេនីយ៍** និង **លោកជំទាវ** ព្រមទាំង **បុត្រា បុត្រី** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ព្រមទាំងទទួលបានសព្វសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសូមសមប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ** ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ ព្រហស្បតិ៍ ១កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មេសា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវិត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh